**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១១៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគផ្ទៃដីទំហំ ៩.៦១៤ ហិកតា មានទីតាំងស្ថិត នៅក្នុងឃុំរយ៉ ស្រុកកោះញែក ខេត្តមណ្ឌលគិរី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងប្បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

- យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ស ម្រេ ច

**មាត្រា១:-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៩.៦១៤ ហិកតា ដែលមានទីតាំងស្ថិតនៅក្នុងឃុំរយ៉ ស្រុកកោះញែក ខេត្តមណ្ឌលគិរី ដើម្បីធ្វើការវិនិយោគដាំដំណាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកាលេខ ៤០១ អនញ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១១ របស់ខេត្តមណ្ឌលគិរី ។

**មាត្រា២:-**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័ន ពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

**មាត្រា៣:-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គ្រប់ក្រសួង ស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

## ផែនទី ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ផេស៊ីហ្វិក ភើល យ៉ិនស្តុក ខមភេនីលីមីធីត
(PACIFIC PEARL JOINT-STOCK COMPANY LIMITED)
### ស្ថិតនៅក្នុង ឃុំយ៉ក ស្រុកកោះញែក ខេត្តមណ្ឌលគិរី




សញ្ញាសំគាល់ :
- ព្រំប្រទល់ដីស្នើសុំ
- ព្រំប្រទល់ខេត្ត
- ផ្លូវទឹក
- ផ្លូវជាតិថ្មី
- ដីជាន់ជាមួយការីអភិវឌ្ឍន៍
- ព្រៃការពារប្រភពទឹក
- ព្រៃការពារទីជម្រាល
- ដីតាមបណ្តោយខាងផ្លូវ

ដំណាំគ្របដណ្តប់ឆ្នាំ២០០២ក្នុងតំបន់ដីមិនកាត់ចេញ:

| | |
|---|---|
| ព្រៃស្រោង | ២ ៦៧៣ ហ.ត |
| ព្រៃពាក់កណ្តាលស្រោង | ២៦៧ ហ.ត |
| ព្រៃល្បោះ | ៦ ២៧៣ ហ.ត |
| ព្រៃល្បោះល្បាយ | ៣២០ ហ.ត |
| ដីគ្មានព្រៃ | ៨១ ហ.ត |
| សរុប : | ៩ ៦១៤ ហ.ត |

ផ្ទៃដីស្នើសុំ: ១១ ១៨០ ហ.ត

ផ្ទៃដីកាត់ចេញ :

| | |
|---|---|
| ព្រៃជាន់ជាមួយការីអភិវឌ្ឍន៍ | ១៤៥ ហ.ត |
| ព្រៃការពារប្រភពទឹក | ១ ៣៦០ ហ.ត |
| ព្រៃការពារទីជម្រាល | ២៧ ហ.ត |
| ដីតាមបណ្តោយខាងផ្លូវ | ៣៥ ហ.ត |

ផ្ទៃដីកាត់ចេញសរុប : ១ ៥៦៧ ហ.ត

ផ្ទៃដីមិនកាត់ចេញ : ៩ ៦១៤ ហ.ត

COORDINATE SYSTEM

| | |
|---|---|
| Projection: | UTM |
| Zone: | 48 |
| Horizontal Datum: | Indian 1960 |
| Spheroid: | Everest |
| UTM Grid: | 2 Km |

N W E S

មាត្រដ្ឋាន ១ : ១០០ ០០០

2 0 2 Km

លេខ ០១៩/១១
បានឃើញ និង ឯកភាព
សូមគោរពជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពិនិត្យ និងសម្រេច
ថ្ងៃ ទី ខែ ឆ្នាំ២០១១
ជិន ខ្លិត

លេខ ១១៥/១១
បានឃើញ និង ឯកភាព
សូមគោរពជូនឯកឧត្តមរដ្ឋមន្ត្រី ពិនិត្យ និងសម្រេច
ថ្ងៃ ទី ខែ ឆ្នាំ២០១១
ម៉ឹង ស៊ឿន

លេខ ៤០៩១ កសក
បានឃើញ និងឯកភាព
គោរពជូន ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពិនិត្យ និងសម្រេច
ថ្ងៃ ទី ខែ ឆ្នាំ២០១១
ចាន់ សឿន

លេខ ១២៥/១១
បានឃើញ និង ឯកភាព
សូមគោរពជូនឯកឧត្តមរដ្ឋមន្ត្រី ពិនិត្យ និងសម្រេច
ថ្ងៃ ទី ខែ ឆ្នាំ២០១១
ប៊ុ. ស៊ុន

លេខ ៦០ ស.ជ.ណ.ល.
បានឃើញ និង ឯកភាព
សូមគោរពជូនឯកឧត្តមរដ្ឋមន្ត្រី ពិនិត្យ និងសម្រេច
ថ្ងៃ ទី ខែ ឆ្នាំ២០១១
ឈឹម ភាន